Australian Government
Services Australia

KHMER

# Disability Support Pension

## សិទ្ធិទទួលបាន

អ្នកប្រហែលជាអាចទទួលបាន **DSP** ប្រសិនបើអ្នកបំពេញតាមទាំងបទប្បញ្ញត្តិផ្នែកវេជ្ជសាស្ត្រ និងមិនមែនវេជ្ជសាស្ត្រ។

អ្នកបំពេញតាមបទប្បញ្ញត្តិមិនមែនវេជ្ជសាស្ត្រ ប្រសិនបើអនុវត្តកត្តាទាំងអស់ខាងក្រោម ហើយអ្នក៖

- មានអាយុចន្លោះ 16 ឆ្នាំ និងអាយុ **age pension (ទទួលប្រាក់សោធននិវត្តន៍មនុស្សចាស់)**
- បំពេញតាមលក្ខខណ្ឌតម្រូវនៃការស្នាក់នៅ
- បំពេញតាមការធ្វើតេស្តប្រាក់ចំណូល និងទ្រព្យសម្បត្តិសម្រាប់ស្ថានភាពរបស់អ្នក។

អ្នកនឹងបំពេញតាមបទប្បញ្ញត្តិផ្នែកវេជ្ជសាស្ត្រ ប្រសិនបើអ្នកមានលក្ខខណ្ឌដោយសម្គាល់មួយដូចខាងក្រោម៖

- អ្នកពិការភ្នែកជាអចិន្ត្រៃយ៍
- អ្នកត្រូវការការថែទាំកម្រិតនៅផ្ទះ
- អ្នកមានជំងឺរង់ចាំតែថ្ងៃស្លាប់ ដោយមានអាយុកាលមធ្យមតិចជាង 2 ឆ្នាំ
- អ្នកមានពិការភាពផ្នែកបញ្ញាជាមួយនឹង IQ តិចជាង 70
- អ្នកមានប្រភេទ 4 HIV/AIDS
- អ្នកទទួល **Department of Veterans' Affairs special rate disability pension (totally and permanently incapacitated) (ប្រាក់សោធននិវត្តន៍ពិការភាពអត្រាពិសេសក្រសួងកិច្ចការអតីតយុទ្ធជន (អសមត្ថភាពទាំងស្រុង និងអចិន្ត្រៃយ៍))**.

ជាជំនួសវិញ អ្នកក៏អាចបំពេញតាមបទប្បញ្ញត្តិផ្នែកវេជ្ជសាស្ត្រ ប្រសិនបើអនុវត្តលក្ខខណ្ឌទាំងអស់ខាងក្រោម៖

- លក្ខខណ្ឌទំនងជាបន្តកើតមានឥតឈប់អាស់រយៈពេលជាង 2 ឆ្នាំ
- លក្ខខណ្ឌរបស់អ្នកត្រូវបានធ្វើរោគវិនិច្ឆ័យ ត្រូវបានព្យាបាល និងធ្វើឱ្យមានស្ថេរភាពសមហេតុផល
- អ្នកបំពេញតាមលក្ខខណ្ឌតម្រូវនៃការវាយតម្លៃភាពចុះខ្សោយ 20 ពិន្ទុ ឬច្រើនជាងនេះ នៅក្រោម **Impairment Tables** (**តារាងភាពចុះខ្សោយ)**
- អ្នកបំពេញតាមបទប្បញ្ញតិ **Program of Support (POS)** (**កម្មវិធីនៃការគាំទ្រ)** ប្រសិនបើអនុវត្តបទប្បញ្ញតិទាំងនេះអនុវត្តចំពោះអ្នក
- លក្ខខណ្ឌរបស់អ្នកនឹងបញ្ឈប់អ្នកមិនឱ្យធ្វើការយ៉ាងតិច 15 ម៉ោង ក្នុងមួយសប្តាហ៍នៅក្នុង 2 ឆ្នាំបន្ទាប់។

## ការទាមទារ DSP

### មុនអ្នកទាមទារ

អ្នកអាចប្រើប្រាស់ **DSP pre-claim guide** (**ការណែនាំមុនទាមទារ DSP)** អាចរកបាននៅលើគេហទំព័ររបស់យើង។ វានឹងមិនប្រាប់អ្នកទេ ប្រសិនបើអ្នកទទួលបានការបង់ប្រាក់ ប៉ុន្តែវានឹងជួយអ្នកសម្រេចថាតើត្រូវទាមទារឬអត់។ ប្រសិនបើអ្នកគិតថាវាជាការបង់ប្រាក់ត្រឹមត្រូវសម្រាប់អ្នក

សូមប្រាកដថាអ្នកមានភស្តុតាងផ្នែកវេជ្ជសាស្ត្រដើម្បីគាំទ្រការទាមទាររបស់អ្នក។
អ្នកក៏អាចត្រូវបំពេញ **POS** នៅមុនអ្នកទាមទារ។

**POS** នឹងជួយអ្នកក្នុង៖

- ការរៀបចំ និងដាក់ពាក្យសុំការងារ
- បទពិសោធន៍ការងារ និង/ឬការបណ្ដុះបណ្ដាល
- ការគ្រប់គ្រងរបួស។

## ពេលវេលាដែលអ្នកទាមទារ

អ្នកត្រូវតែផ្ដល់ឱ្យយើងនូវភស្តុតាងផ្នែកវេជ្ជសាស្ត្រ យើងនឹងប្រើប្រាស់ភស្តុតាងនេះដើម្បី
វាយតម្លៃសិទ្ធិទទួលបានសម្រាប់ **DSP**។ អ្នកអាចត្រូវការចូលរួមក្នុងការវាយតម្លៃនានា។
នៅពេលអ្នកត្រៀមខ្លួនរួចរាល់ដើម្បីដាក់បញ្ជូនការទាមទារ វិធីដែលលឿនបំផុតគឺតាមអនឡាញ។
ប្រសិនបើអ្នកមានរួចហើយនូវ **Centrelink Customer Reference Number (CRN),**
(**លេខឯកសារយោងអតិថិជន**), អ្នកអាចទាមទារតាមអនឡាញ
ជាមួយ **Centrelink** តាមរយៈគណនី **myGov** របស់អ្នក។

ប្រសិនបើអ្នកមិនមាន **CRN**, សូមទៅកាន់ **my.gov.au** ដើម្បីទទួលបានវាមួយ។
អ្នកមិនត្រូវការទៅមជ្ឈមណ្ឌលសេវាកម្មទេ។ ប្រសិនបើអ្នកមានអ្នកដែលគេតែងតាំងឱ្យធ្វើទំនាក់ទំនង
ពួកគេអាចទាមទារសម្រាប់អ្នកតាមអនឡាញ។
ប្រសិនបើអ្នកមិនមានអ្នកដែលគេតែងតាំងឱ្យធ្វើទំនាក់ទំនងទេ ហើយអ្នកចង់បានវាមួយ
អ្នកត្រូវតែបង្កើតវា។ សម្រាប់ព័ត៌មានបន្ថែមអំពីការចាត់ចែងអ្នកដែលគេតែងតាំង
សូមទៅកាន់ **servicesaustralia.gov.au/nominees**

## នៅពេលយើងវាយតម្លៃការទាមទាររបស់អ្នក

### Job Capacity Assessment

ជាផ្នែកនៃដំណើរការទាមទាររបស់អ្នក អ្នកនឹងត្រូវការចូលរួមក្នុង **Job Capacity Assessment (JCA,**
**ការវាយតម្លៃសមត្ថភាពការងារ)**។ **JCA** នឹងវាយតម្លៃផលប៉ះពាល់នៃស្ថានភាពផ្នែកវេជ្ជសាស្ត្រ
និងពិការភាពលើសមត្ថភាពរបស់អ្នកដើម្បីធ្វើការ និងថាតើអ្នកទទួលបានអត្ថប្រយោជន៍ពី
ជំនួយការងារឬអត់។ មិនមានការចំណាយសម្រាប់ការវាយតម្លៃនេះទេ។

### Disability Medical Assessment

បន្ទាប់ **JCA** របស់អ្នកហើយ យើងអាចបញ្ជូនអ្នកបន្តទៅ **Disability Medical Assessment (DMA),**
**(ការវាយតម្លៃផ្នែកវេជ្ជសាស្ត្រនៃពិការភាព)**។
**DMA** ដើម្បីជួយយើងសម្រេចថាសិទ្ធិទទួលបានផ្នែកវេជ្ជសាស្ត្ររបស់អ្នកសម្រាប់ **DSP**។
វេជ្ជបណ្ឌិតជាប់កិច្ចសន្យាជាមួយរដ្ឋាភិបាលនឹងដឹកនាំធ្វើ **DMA**របស់អ្នក។
វេជ្ជបណ្ឌិតនេះនឹងមិនមែនជាវេជ្ជបណ្ឌិតធម្មតារបស់អ្នកទេ ដូច្នេះពួកគេអាចទាក់ទងវេជ្ជបណ្ឌិតរបស់អ្នក
ប្រសិនបើពួកគេត្រូវការព័ត៌មានបន្ថែមទៀត។ វេជ្ជបណ្ឌិតជាប់កិច្ចសន្យាជាមួយរដ្ឋាភិបាល
ទាំងអស់មានគុណវុឌ្ឍិ និងទទួលបានការបណ្ដុះបណ្ដាលដើម្បីធ្វើការវាយតម្លៃទាំងនេះ។
មិនមានការចំណាយសម្រាប់ការវាយតម្លៃនេះទេ។

## លទ្ធផលនៃការទាមទារ DSP របស់អ្នក

យើងនឹងប្រាប់ឱ្យអ្នកដឹង ប្រសិនបើការទាមទាររបស់អ្នកបានជោគជ័យ។ ប្រសិនបើអ្នកមាន
សិទ្ធិទទួល **DSP**, យើងនឹងប្រាប់ឱ្យអ្នកនៅពេលណាការបង់ប្រាក់របស់អ្នកនឹងចាប់ផ្ដើម ហើយ
ចំនួនប៉ុន្មានដែលអ្នកនឹងទទួលបានការបង់ប្រាក់។ មិនមែនមនុស្សគ្រប់រូបដែលមានពិការភាព
ឬស្ថានភាពផ្នែកវេជ្ជសាស្ត្រអាចទទួលបាន **DSP**ទេ។ ប្រសិនបើអ្នកមិនអាចទទួលបានវាទេ
អ្នកប្រហែលជាអាចទទួលបានការបង់ប្រាក់ដទៃទៀត។

## សម្រាប់ព័ត៌មានបន្ថែម

- ទៅកាន់ **servicesaustralia.gov.au/dsp** សម្រាប់ព័ត៌មានបន្ថែមជាភាសាអង់គ្លេស
- សូមទៅកាន់ **servicesaustralia.gov.au/yourlanguage** ដែលជាកន្លែងអ្នកអាចអាន ស្តាប់ ឬមើលវីដេអូដែលមានព័ត៌មានជាភាសារបស់អ្នក
- ហៅទូរសព្ទទៅលេខ **131 202** ដើម្បីនិយាយជាមួយយើងជាភាសារបស់អ្នកផ្ទាល់អំពីការបង់ប្រាក់ និងសេវាកម្ម **Centrelink**
- សូមហៅទូរសព្ទទៅលេខ **132 011** សម្រាប់ **Medicare** និងលេខ **131 272** សម្រាប់ **Child Support**។ សូមប្រាប់ឱ្យយើងដឹងប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ ហើយយើងនឹងចាត់ចែងឱ្យមានអ្នកបកប្រែផ្ទាល់មាត់ដោយឥតគិតថ្លៃ។
- ចូលទៅទស្សនាមជ្ឈមណ្ឌលសេវាកម្ម។

ចំណាំ៖ ការហៅទូរសព្ទពីទូរសព្ទផ្ទះរបស់អ្នកទៅ ‘13’ លេខពីកន្លែងណាមួយនៅក្នុងប្រទេសអូស្ត្រាលី គឺត្រូវបានគិតថ្លៃតាមអត្រាថេរ។ អត្រានោះអាចប្រែប្រួលពីតម្លៃនៃការហៅទូរសព្ទតាមតំបន់ ហើយក៏អាចប្រែប្រួលផងដែរក្នុងចំណោមអ្នកផ្តល់សេវាទូរសព្ទនានា។ ហៅទូរសព្ទទៅលេខ ‘1800’ ពីទូរសព្ទផ្ទះរបស់អ្នកគឺឥតគិតថ្លៃ។ ការហៅទូរសព្ទពីទូរសព្ទសាធារណៈ និងពីទូរសព្ទចល័ត អាចត្រូវបានកំណត់ម៉ោង ព្រមទាំងត្រូវបានគិតថ្លៃតាមអត្រាកាន់តែខ្ពស់។

## ការប្រកាសមិនទទួលខុសត្រូវ

ព័ត៌មានដែលមាននៅក្នុងការបោះផ្សាយនេះមានគោលបំណងតែជាការណែនាំចំពោះការបង់ប្រាក់ និងសេវាកម្មនានាប៉ុណ្ណោះ។ វាជាការទទួលខុសត្រូវរបស់អ្នកក្នុងការសម្រេចចិត្ត ប្រសិនបើអ្នកប្រាថ្នាចង់ដាក់ពាក្យដើម្បីទទួលបានការបង់ប្រាក់ និងដើម្បីធ្វើការដាក់ពាក្យសុំទាក់ទងនឹងកាលៈទេសៈពិសេសរបស់អ្នក។

# Disability Support Pension

## Eligibility

You may be able to get **DSP** if you meet both non-medical and medical rules.

You will meet the non-medical rules if all the following apply and you:

• are between 16 years of age and **age pension** age

• meet the residence requirements

• meet the income and assets tests for your situation.

You will meet the medical rules if you have one of the following manifest conditions:

• you are permanently blind

• you need nursing home level care

• you have a terminal illness with average life expectancy of less than 2 years

• you have an intellectual disability with an IQ of less than 70

• you have category 4 HIV/AIDS

• you get a **Department of Veterans' Affairs special rate disability pension (totally and permanently incapacitated)**.

Alternatively, you may also meet the medical rules if all of the following apply:

• your condition is likely to persist for more than 2 years

• your condition is diagnosed, reasonably treated and stabilised

• you meet the impairment rating requirement of 20 points or more under the **Impairment Tables**

• you meet **Program of Support (POS)** rules, if these apply to you

• your condition will stop you working at least 15 hours a week in the next 2 years.

## Claiming DSP

### Before you claim

You can use our **DSP pre-claim guide** available on our website. It will not tell you if you can get the payment, but it will help you decide whether to claim. If you think it is the right payment for you, make sure you have medical evidence to support your claim. You may also need to complete a **POS** before you claim.

A **POS** will help you with:

• preparing for and applying for jobs

• work experience and/or training

• injury management.

## When you claim

You must give us medical evidence. We will use this evidence to assess your eligibility for **DSP**. You may need to attend assessments. When you are ready to submit a claim, the quickest way to claim is online. If you already have a **Centrelink Customer Reference Number (CRN)**, you can claim online with **Centrelink** through your **myGov** account.

If you do not have a **CRN**, go to **my.gov.au** to get one. You do not need to visit a service centre. If you have a correspondence nominee, they can claim for you online. If you do not have a correspondence nominee, and you want one, you must set this up. For more information about nominee arrangements, go to **servicesaustralia.gov.au/nominees**

## When we assess your claim

### Job Capacity Assessment

As part of your claim process, you will need to attend a **Job Capacity Assessment (JCA)**. A **JCA** will assess the impact of your medical conditions and disabilities on your ability to work and whether you would benefit from employment assistance. There is no cost for this assessment.

### Disability Medical Assessment

Following your **JCA**, we may refer you to a **Disability Medical Assessment (DMA)**. A **DMA** helps us to decide your medical eligibility for **DSP**. A Government-contracted doctor will conduct your **DMA**. This doctor will not be your usual doctor, though they may contact your doctor if they need more information. All Government-contracted doctors are qualified and trained to do these assessments. There is no cost for this assessment.

## Outcome of your **DSP** claim

We will let you know if your claim is successful. If you are eligible for **DSP**, we will tell you when your payment will start and how much you will get paid. Not everyone with disability or a medical condition can get **DSP**. If you cannot get it you may be able to get other payments.

# For more information

- Go to **servicesaustralia.gov.au/dsp** for more information in English
- Go to **servicesaustralia.gov.au/yourlanguage** where you can read, listen to or watch videos with information in your language
- Call **131 202** to speak with us in your own language about **Centrelink** payments and services
- Call **132 011** for **Medicare** and **131 272** for **Child Support**. Let us know if you need an interpreter, and we will arrange one for free
- Visit a service centre.

Note: calls from your home phone to ‘13’ numbers from anywhere in Australia are charged at a fixed rate. That rate may vary from the price of a local call and may also vary between telephone service providers. Calls to ‘1800’ numbers from your home phone are free. Calls from public and mobile phones may be timed and charged at a higher rate.

## Disclaimer

The information contained in this publication is intended only as a guide to payments and services. It's your responsibility to decide if you wish to apply for a payment and to make an application with regard to your particular circumstances.